# ការិយាល័យលេខាធិការជាតិ

## ការឆ្លើយតបគោលនយោបាយជាសាធារណៈ ចំពោះជំងឺកូវីដ-១៩ - កំណត់សម្គាល់សង្ខេប

ធីម ខេនណឺឌី | ២២ មិនា ២០២០

### សេចក្តីផ្តើម

ដោយសារតែផលប៉ះពាល់នៃជំងឺកូវីដ-១៩ នៅបន្តរីករាលដាលនៅជុំវិញពិភពលោកនោះ យើងត្រូវតែចាត់វិធានការ ដើម្បីអភិវឌ្ឍនិងកែលម្អការឆ្លើយតបចំពោះវិបត្តិនេះ ប្រកបដោយភាពរួបរួមគ្នានិងប្រកបដោយប្រសិទ្ធភាព។ ចលនាសហជីពអូស្ត្រាលី ស្ថិតនៅក្នុងស្ថានភាពមួយជាពិសេស ក្នុងការឈ្វេងយល់អំពីតម្រូវការរបស់សមាជិកនិងអ្នកធ្វើការងាររបស់យើង នៅក្នុងអំឡុងពេលនេះ។

### សារតារ

សហជីពកម្មកររួបរួម ត្រូវបានបង្កើតឡើងដើម្បីសាងឡើងវិញនូវអំណាចរបស់អ្នកធ្វើការងារ និងដើម្បីបង្កើតការផ្លាស់ប្តូរជាអចិន្ត្រៃយ៍មួយ សម្រាប់មនុស្សជាច្រើន គឺមិនមែនសម្រាប់មនុស្សតិចតួចនោះទេ។ របៀបដែលយើងឆ្លើយតបនិងតស៊ូជាមួយកម្មករនាពេលបច្ចុប្បន្ននេះ អាចបង្កើតការផ្លាស់ប្តូរអចិន្ត្រៃយ៍ ទៅលើប្រព័ន្ធដែលមិនមានប្រសិទ្ធភាពសម្រាប់មនុស្ស៩៩%ទៀតហើយនោះ។

គ្រាដែលមានការប្រេះស្រាំ បង្កើតនូវលំហនិងការវិវត្តឆាប់រហ័សមួយ សម្រាប់ការផ្លាស់ប្តូរ ដូច្នេះ យើងមិនត្រូវខ្ជះខ្ជាយវិបត្តិណាមួយនោះទេ។

ខណៈដែលវាហាក់ដូចជាលឿនពេកក្នុងការទស្សទាយថាតើវិបត្តិនេះ នឹងវិវត្តទៅជាបែបណាឲ្យពិតប្រាកដនោះ យើងបានដឹងតាមប្រវត្តិសាស្ត្រមកថា ចលនាប្រឆាំងកម្មករ ក៏មានការកៀងគរក្នុងអំឡុងពេលសភាពការណ៍បែបនេះ ក្នុងការប៉ុនប៉ង ដើម្បីពង្រឹងប្រព័ន្ធបន្ថែមទៀត ក្នុងការលួចប្រាក់ឈ្នួល និងការកេងប្រវ័ញ្ចដែលបន្ទាបតម្លៃកន្លែងធ្វើការដែលទាបរួចស្រាប់ហើយនោះ។

ស្ថានភាពដែលកំពុងមានក្នុងពេលបច្ចុប្បន្ននេះ តែងតែមិនស្មើភាពគ្នារួចស្រេចហើយ។ វិបត្តិនេះ បានលាតត្រដាងឲ្យឃើញច្បាស់ថា វាក៏មិនអាចការពារបានដែរ។

### ដំណោះស្រាយបន្ទាន់

រួមគ្នា យើងអាចបោះជំហានទៅមុខ នូវចក្ខុវិស័យជំនួសមួយដែលមានការរីកចម្រើនជាលំដាប់ ដែលសមាជិករបស់យើងមានទឹកចិត្តក្នុងការតស៊ូដើម្បីធ្វើឲ្យបានសម្រេច។ ជំហានទីមួយ គឺការឆ្លើយតបផ្នែកសេដ្ឋកិច្ចបន្ទាន់មួយ ដោយមានធាតុផ្សំបី គឺប្រាក់ចំណូល ការវិនិយោគ និងភាពជាម្ចាស់។

១. **ប្រាក់ចំណូល៖** ប្រាក់ចំណូលជាគោល គឺជាការផ្តល់ប្រាក់ដែលមានការធានាមួយ ដែលផ្តល់ឲ្យក្នុងកម្រិតបុគ្គល (ជាជាងកម្រិតគ្រួសារ)។ ការផ្តល់ប្រាក់នេះ គឺមិនត្រូវមានលក្ខខណ្ឌទេ មានន័យថា

អ្នកទទួលមិនចាំបាច់ត្រូវធ្វើការ ឬបង្ហាញឆន្ទៈក្នុងការធ្វើការទេ ហើយវាក៏មិនមែនជាការផ្តល់ប្រាក់ដែលជាការធ្វើតេស្ត៍ទៅលើមធ្យោបាយនោះដែរ។

សហជីពកម្មកររួបរួម ស្នើឲ្យមានការផ្តល់ប្រាក់ចំណូលជាគោល ដែលផ្តល់ដល់អ្នកដែលទទួលរងគ្រោះផ្នែកហិរញ្ញវត្ថុដោយសារជំងឺកូវីដ-១៩ ទោះបីជាពួកគេមានការងារដែលមានប្រាក់ចំណូល ឬមិនមាន មុនពេលជំងឺកូវីដ-១៩ ផ្ទុះឡើងនោះ រហូតដល់ចុងឆ្នាំ ២០២០ នៅពេលដែលគេអាចប៉ាន់ប្រមាណនិងស្តាបនាលើស្ថានការណ៍ឡើងវិញបាន។

កម្មករដែលមិនទទួលរងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ដូចជាអ្នកដែលអាចធ្វើការពីផ្ទះបាន ដោយមិនបាត់បង់ប្រាក់កម្រៃ ឬអ្នកដែលអាចទទួលបានការផ្តល់នូវការសម្រាកបន្តបន្ទាប់ជាពិសេសពីនិយោជក នឹងត្រូវលើកលែងពីការទទួលបានប្រាក់ចំណូលគោល ដោយសារតែពួកគេមិនបានទទួលរងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុនោះទេ។

សកម្មភាពទាក់ទងនឹង **ការទាមទារការធានាប្រាក់ចំណូល គឺជាការងារ ដែលអ្នកអាចគិតត្រូវធ្វើ**

**ការងារដែលអ្នកអាចគិតត្រូវធ្វើ** មិនមែនអំពីការងារពេញម៉ោងឬជាគោលនយោបាយអ្នកធ្វើការក្នុងវិស័យការងារនោះទេ ប៉ុន្តែ វាទាក់ទងនឹងសន្តិសុខនិងភាពថ្លៃថ្នូរសម្រាប់អ្នកធ្វើការងារ។ ក្នុងអំឡុងពេលមានវិបត្តិនិងអសន្តិសុខនោះ សន្តិសុខជាគោល គឺសម្រាប់ភាពល្អជាសាធារណៈជាធម្មជាតិមួយ។ វាមិនមានអ្វីដែលត្រូវប្រជែងនោះទេ មានន័យថា ការដែលអ្នកមានសន្តិសុខ មិនធ្វើឲ្យសន្តិសុខរបស់អ្នកធ្លាក់ចុះទាបនោះទេ គឺតាមពិតទៅ យើងទទួលបានពីអ្នកផ្សេងទៀតដែលកំពុងមានសន្តិសុខ។

សន្តិសុខផ្នែកសេដ្ឋកិច្ច បង្កើនកម្រិតសាមគ្គីភាពសង្គមនិងការចូលរួមក្នុងកម្លាំងការងារកាន់តែខ្លាំង ហើយជាលទ្ធផល វានឹងបង្កើតលក្ខខណ្ឌក្នុងការចងក្រង និងចាត់វិធានការដើម្បីឈ្នះនិងទទួលបានភាពចំណេញ។

សម្រាប់មនុស្សជាច្រើន សន្តិសុខអាចជាបុរេលក្ខខណ្ឌសម្រាប់ធ្វើឲ្យមានសាមគ្គីភាព។ ចលនានៃសន្តិសុខនិងហានិភ័យតាមទម្រង់សេរីភាពបែបថ្មី (តាមរយៈការងារដែលគ្មានសន្តិសុខ) ទាក់ទងនឹងមូលធនរបស់បុគ្គល គឺជាកម្លាំងចលករសំខាន់មួយនៃវិសមភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។ ការភ័យខ្លាចនិងអសន្តិសុខ ក៏ធ្វើឲ្យទន់ខ្សោយដល់សាមគ្គីភាពសង្គមដែរ។

ប្រាក់ចំណូលគោល ជួយទប់ទល់ប្រឆាំងនឹងភាពភ័យខ្លាច។

ទ្រព្យសម្បត្តិភាគច្រើនបំផុត មិនហូរចេញពីប្រាក់ឈ្នួលទេ។ យើងមានរបបសង្គមនិយមសម្រាប់អ្នកមាន រួចហើយ។

សម្រាប់មនុស្សជាច្រើន គំនិតអំពីការទទួលបានប្រាក់កម្រៃនៅពេលដែលអ្នកមិនធ្វើការ គឺជាគំនិតចម្លែក។ ប៉ុន្តែ យើងត្រូវចងចាំថា ក្រោមរបបមូលធននិយមដែលទទួលលាភសក្ការៈពីទ្រព្យនិងការវិនិយោគនោះ ប្រាក់ចំណូលភាគច្រើន មិនអាស្រ័យទៅលើប្រាក់ឈ្នួលនោះទេ។ វាហូរមកពីភាពជា

ម្ចាស់ទៅលើទ្រព្យ ទោះជាទ្រព្យនោះស្ថិតក្នុងទម្រង់រូបវ័ន្ត ហិរញ្ញវត្ថុ ឬបញ្ញាក៏ដោយ។ ក្រុមដែលមានទ្រព្យតិចនោះ គឺផ្សារភ្ជាប់ទៅនឹងប្រាក់ឈ្នួល ហើយយើងបានឃើញផលទទួលបានពីប្រាក់ឈ្នួលទាំងនេះ មានការជាប់នឹងថ្កល់អស់រយៈពេលជិតបួនទសវត្សហើយ។

**<u>គំនិតអំពីប្រាក់ចំណូលគោលសាកល (UBI)</u>**

ខណៈដែលជំហរនេះ ត្រូវបានតស៊ូមតិដោយសហជីពកម្មកររួបរួមនោះ នៅគ្រានេះនៃវិបត្តិ វាមិនមែនជាការតស៊ូមតិដើម្បីប្រាក់ចំណូលគោលសាកលនោះទេ ប៉ុន្តែ គឺជាប្រាក់ចំណូលគោល ក្នុងអាត្រាប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករទាំងអស់ (តាមនិយមន័យទូលាយ) ដែលទទួលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩។ បញ្ហាប្រឈមទីពីរដែលលើកឡើងដោយអត្ថបទនេះ គឺថា ប្រសិនបើយើងមានភាពម៉ត់ចត់ក្នុងការការផ្លាស់ប្តូររចនាសម្ព័ន្ធអំណាចដែលចង់រក្សាប្រព័ន្ធបរាជ័យមួយនេះ យើងនឹងត្រូវការបង្កើតការឆ្លើយតបជាសាកលមួយដើម្បីផលប្រយោជន៍របស់វណ្ណៈកម្មករ។

ប្រាក់ចំណូលគោល មិនមែនជាប្រាក់ឈ្នួលទេ ប៉ុន្តែជាភាគលាភសង្គមទៅលើទ្រព្យសម្បត្តិសមូហភាពរបស់យើងទាំងអស់គ្នា។

យើងជាជនក្នុងវណ្ណៈអ្នកធ្វើការ។ សូម្បីតែយើង មិនត្រូវជួលឲ្យធ្វើការងារក៏ដោយ ក៏យើងតែងតែធ្វើការងារនៅក្នុងផ្ទះ និងក្នុងសហគមន៍។ ការងារដែលផ្តល់ប្រាក់ឈ្នួល មិនមែននិយមម័យសម្រាប់យើងនោះទេ ហើយសមត្ថភាពរបស់យើងក្នុងការរស់នៅ មិនគួរអាស្រ័យទៅលើវានោះដែរ។

សហជីពនិងអង្គការអន្តរជាតិខាងការងារ ជារឿយៗ ប្រកាសថា ការងារមិនមែនជាទំនិញទេ ប៉ុន្តែយើងបានចងភ្ជាប់ទៅនឹងការផ្តល់ផ្នែកសង្គមជាមូលដ្ឋាន ក្នុងការមានការងារមួយ។ ប្រាក់ចំណូលគោលសាកល ជាជំហានអនុវត្តមួយ ក្នុងការឈានទៅដល់ការងារមួយដែលមិនមែនជាទំនិញ ព្រមទាំងបង្កើតសន្តិសុខមួយដែលយើងត្រូវការ ដើម្បីកសាងសាមគ្គីភាព និងលក្ខខណ្ឌ ដើម្បីចងក្រងនិងចាត់វិធានការ។

២. **ការវិនិយោគ៖ ហ្វាទីស ប៊ីរ៉ូល** ប្រធានទីភ្នាក់ងារថាមពលអន្តរជាតិ (IEA) ថ្លែងថា យើងមាន "ឱកាសជាប្រវត្តិសាស្ត្រសម្រាប់ពិភពលោក ទីមួយ ក្នុងការបង្កើតកញ្ចប់នានា ដើម្បីស្តារសេដ្ឋកិច្ច និងមួយទៀត ដើម្បីកាត់បន្ថយការវិនិយោគកខ្វក់និងពន្លឿនការផ្លាស់ប្តូរការប្រើប្រាស់ថាមពល"។

កម្រិតនៃការជំនួយហិរញ្ញវត្ថុសង្គ្រោះ មិនត្រឹមតែត្រូវឈានឲ្យដល់កម្រិតនៃវិបត្តិកូវីដ-១៩ នោះទេ ប៉ុន្តែ ទិសដៅនៃការផ្តល់មូលនិធិនេះ គួររួមបញ្ចូល មិនត្រឹមតែការចំណាយសង្គមដែលសំខាន់ចាំបាច់នោះទេ វាថែមទាំងត្រូវមានហេដ្ឋារចនាសម្ព័ន្ធថាមពលថ្មី ដែលពិភពលោកត្រូវការ ដូចជាការបង្កើតថាមពលកកើតឡើងវិញបានក្នុងទ្រង់ទ្រាយធំ បង្កើតការផ្ទុកថាមពល បង្កើតអាងកាបូនប្រទេសអូស្ត្រាលី និងកសាងសមត្ថភាពក្នុងការនាំចេញអ៊ីដ្រូសែននៅកម្រិតដ៏ធំសំខាន់មួយ។

វាសំខាន់ណាស់ដែលការងារស្តីពីការបង្កើតថាមពលកើតឡើងវិញ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការនាំចេញ ត្រូវចាប់ផ្តើមយ៉ាងឆាប់រហ័ស ដើម្បីជួយមនុស្សបានត្រឡប់ទៅធ្វើការងារវិញឲ្យបានកាន់តែឆាប់។ លើសពីនេះទៀត វាជាការចាំបាច់ណាស់ដែលកម្មករ នៅក្នុងតួនាទីទាំងនេះ មាន

ទាំងសុវត្ថិភាពការងារ និងសិទ្ធិសហជីពសមរម្យមួយ តាំងពីថ្ងៃទីមួយទៅ។ ការចូលរួមពាក់ព័ន្ធនៅគ្រប់ចំណុចនិមួយៗ នឹងធានាថា កន្លែងការងារទីនេះ មិនធ្លាក់ចូលទៅក្នុងចំណុចថ្មីម្តងទៀតនៃការចម្លងមេរោគកូវីដ១៩។

**៣. ភាពជាម្ចាស់៖** មូលនិធិសាធារណៈណាដែលទៅដល់វិស័យសាជីវកម្ម និងអន្តរាគមន៍ផ្សេងទៀតរបស់រដ្ឋាភិបាល ដែលធ្វើឡើងដើម្បីអត្ថប្រយោជន៍របស់ពួកគេ គួរមានចែងឲ្យបានច្បាស់អំពីការទទួលខុសត្រូវ ក្នុងការធ្វើឲ្យមានការធ្វើសេចក្តីសម្រេចកាន់តែតាមលក្ខណៈប្រជាធិបតេយ្យ នៅក្នុងក្រុមហ៊ុន។ ការធ្វើបែបនេះ អាចមានន័យនិងលក្ខណៈផ្សេងៗគ្នា អាស្រ័យតាមវិស័យ។ វិស័យសំខាន់ៗដែលផលិតទំនិញឬសេវាកម្ម ដែលសង្គមត្រូវផ្អែកទៅលើជាសាកល គួរស្ថិតនៅក្រោមភាពជាម្ចាស់សាធារណៈ ដែលរួមបញ្ចូលទាំងក្រុមហ៊ុនក្នុងវិស័យដូចខាងក្រោម៖

- ថាមពល
- សុខភាព និងការថែទាំ
- ការអប់រំកុមារតូច
- គមនាគមន៍
- ការដឹកជញ្ជូន និងភស្តុភារ

ភាពជាម្ចាស់សាធារណៈនេះ មិនគួរត្រឡប់ទៅរកភាពជាស្ថាប័នបែបចាស់គំរិលដែលមានការសម្រេចពីលើចុះក្រោមនោះទេ ប៉ុន្តែ គួរមានតួនាទីរបស់កម្មករនិងអតិថិជន នៅក្នុងការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យសម្រាប់ស្ថាប័នទាំងនេះ។

នៅកន្លែងដែលមិនសមស្របក្នុងការនាំយកក្រុមហ៊ុនមួយចំនួន ទៅដាក់ក្រោមភាពជាម្ចាស់សាធារណៈពេញលេញនោះ ការប្រើប្រាស់មូលនិធិសាធារណៈ គួរភ្ជាប់មកជាមួយកាតព្វកិច្ច ឲ្យក្រុមហ៊ុនចូលរួមពាក់ព័ន្ធនៅក្នុងការប្តេជ្ញាចិត្តរួមគ្នា។ នេះមានន័យថា មួយភាគបីនៃតួនាទីក្រុមប្រឹក្សាភិបាលទាំងអស់នៅក្នុងក្រុមហ៊ុនដែលទទួលបាន ការជួយសង្គ្រោះផ្នែកសាជីវកម្ម ជាផ្នែកមួយនៃវិបត្តិនេះ គួរបានទៅដល់បុគ្គលិកមិនស្ថិតនៅថ្នាក់គ្រប់គ្រងរបស់ក្រុមហ៊ុន។ នេះជាវិធីគន្លឹះមួយ ដើម្បីធានាថា លុយសាធារណៈ មិនត្រូវបានគេប្រើសម្រាប់ការទិញហ៊ុនត្រឡប់ ការចំណាយសម្រាប់ថ្នាក់គណៈប្រតិបត្តិ ឬជាមូលនិធិប្រយុទ្ធដើម្បីបន្ទាបប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារឡើយ។

សហជីពកម្មកររួបរួម ជឿជាក់និងទុកចិត្ត ទៅលើសមត្ថភាពរបស់កម្មករក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយភាពឆ្លាតវៃ និងទាមទារឲ្យនិយោជកមានគណនេយ្យភាពចំណោះផលប្រយោជន៍សាធារណៈ។

ឧទាហរណ៍ជាសាធារណៈជាក់ស្តែងបំផុត គឺ ការផ្តល់លុយចំនួនច្រើនជាង ៧០០ លានដុល្លារ ដល់ក្រុមហ៊ុនអាកាសចរដែលមានម្ចាស់ជាសាធារណៈ គឺក្រុមហ៊ុនអាកាសចរក្វាន់តាស។

ជាចុងក្រោយ នៅក្នុងវិស័យឯករាជ្យ ដែលសំខាន់ខ្លាំងសម្រាប់មុខងារសង្គម កំពុងជួបប្រទះនឹងបញ្ហាប្រឈមលក្ខណៈរចនាសម្ព័ន្ធ និងមិនមានការសមស្របចាំបាច់សម្រាប់ការផ្តាច់មុខជាសាធារណៈនោះ មូលនិធិ

សាធារណៈ គួរត្រូវបានប្រើ ដើម្បីជំរុញការជម្រុះចោលការធ្វើសាជីវកម្មនីយកម្ម និងការផ្លាស់ប្តូររចនាសម្ព័ន្ធអាជីវកម្មដែលកាន់កាប់ភាគច្រើនដោយម្ចាស់ហ៊ុននិងអតិថិជន។

វិស័យបែបនេះ រួមមាន កសិកម្ម ការកែច្នៃម្ហូប បដិសណ្ឋារកិច្ច និងផ្នែកមួយចំនួននៃការថែទាំសង្គម។ ម៉ូដែលសហករណ៍ បានធ្វើឲ្យទីជនបទនិងតាមតំបន់មួយចំនួននៃប្រទេសអូស្ត្រាលី មានភាពរឹងមាំ អស់រយៈពេលច្រើនជំនាន់មកហើយ។ វាគឺជាអាជីវកម្មដ៏ធន់មួយ ដែលមានភាពងាយនឹងសម្របខ្លួននៅពេលដែលមានវិបត្តិ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធនៅកន្លែងដែលត្រូវការចាំបាច់នេះ គួរធ្វើឡើងនៅលើមូលដ្ឋាននៃការដាក់បញ្ចូលរាល់សហគមន៍ដែលពាក់ព័ន្ធទាំងអស់ដែលមានផលប្រយោជន៍ ដូចជា កសិករ កម្មករ ម្ចាស់និងអតិថិជនតាមលក្ខណៈប្រពៃណី។

## តម្រូវការ/ការទាមទារ

យើងអំពាវនាវឲ្យរដ្ឋាភិបាលសហព័ន្ធ អន្តរាគមន៍និងដើរតួនាទីសកម្មមួយក្នុងការធានានិងផ្តល់សន្តិសុខសង្គមនិងសេដ្ឋកិច្ច ក្នុងអំឡុងពេលនេះ។

ភាពឡូស៊ិកផ្នែកទីផ្សារនៃការបង្កើតប្រាក់ចំណេញឲ្យដល់កម្រិតអតិបរមា និងការបែងចែកមិនស្មើភាពគ្នាត្រូវតែលុបបំបាត់ចោល និងត្រូវការផ្តល់នូវការទាមទារតម្រូវការសំខាន់ៗចំនួនបី។

### ១. សុវត្ថិភាពសម្រាប់កម្មករ

➢ <u>*ការផ្តល់ប្រាក់ចំណូលគោល*</u>

ធានាថាប្រាក់ចំនួន $៧៤០.៨០ ក្នុងមួយសប្តាហ៍ (ប្រាក់ឈ្នួលអប្បបរមា) ត្រូវផ្តល់ទៅឲ្យកម្មករដែលទទួលរងផលប៉ះពាល់ដោយសារកូវីដ-១៩ សម្រាប់ហេតុផល ដូចជា មិនអាចធ្វើការពីផ្ទះបាន បាត់បង់ការងារ ជំងឺ ឬការដាក់ខ្លួនឯកោដោយមិនមានប្រាក់កម្រៃ។

ការផ្តល់នេះ រួមបញ្ចូលរាល់កម្មករទាំងអស់ រួមទាំងការងារធម្មតា ការជួលពលកម្ម អ្នកធ្វើការងារខ្លួនឯង អ្នកម៉ៅការ និងកម្មករការងារ និងអ្នកធ្វើការឯករាជ្យនានា ដោយមិនគិតថាមានសញ្ជាតិអ្វី ឋានៈប្រភេទទិដ្ឋាការបែបណា ឬមិនមានទិដ្ឋាការនោះទេ។ ខណៈយើងខ្ញុំស្វាគមន៍ សេចក្តីជូនដំណឹងកាលពីថ្ងៃទី២២ ខែមិនា របស់រដ្ឋាភិបាល ក្នុងការបង្កើនទ្វេរដងនូវអាត្រាប្រាក់ឈ្នួលរបស់ Newstart នោះ យើងខ្ញុំអះអាងថា ប្រាក់ឈ្នួលអប្បបរមា ជាប្រាក់ឈ្នួលបាតសមស្របជាង។

➢ <u>*ពង្រឹងការថែទាំវេជ្ជសាស្ត្រ*</u>

ធានាឲ្យមានការទទួលបានការថែទាំវេជ្ជសាស្ត្រ ដល់មនុស្សគ្រប់គ្នា ដែលកំពុងនៅប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ន ដោយរួមទាំងអ្នកកាន់ទិដ្ឋាការ និងកម្មករមិនមានឯកសារសមស្រប។

➢ <u>*ភាពស្មើគ្នាសម្រាប់អ្នកទទួលសុខុមាលភាព*</u>

បង្កើនអត្ថប្រយោជន៍ Newstart និង Centrelink ជាបន្ទាន់ ដើម្បីធានាថាបុគ្គលគ្រប់រូប កំពុងទទួលបាន យ៉ាងហោចណាស់ប្រាក់ឈ្នួលអប្បបរមា។

➢ <u>*ការបង្កើនកម្រិតដែលត្រូវរួចពន្ធ*</u>

សូមបង្កើនកម្រិតដែលត្រូវរួចពន្ធជាបណ្ដោះអាសន្ន ពី $១៨,២០០ ទៅ $២៥,០០០ ដើម្បីជួយដល់អ្នកដែលមានប្រាក់ចំណូលទាបបំផុតនៅក្នុងប្រទេស។

➢ *ការផ្អាកបណ្ដោះអាសន្នសម្រាប់ការបង់ថ្លៃជួលផ្ទះនិងការបង់រំលោះ*

សូមអនុវត្តការផ្អាកបណ្ដោះអាសន្នសម្រាប់ការបង់ថ្លៃជួលផ្ទះនិងការបង់រំលោះជាបន្ទាន់។ យើងខ្ញុំស្វាគមន៍ សេចក្ដីជូនដំណឹងកាលពីថ្ងៃទី២០ ខែមិនា របស់រដ្ឋាភិបាល ក្នុងការការពារអ្នកជួលពីការបណ្ដេញចេញ ក្នុងអំឡុងពេលនេះ។

## ២. សុវត្ថិភាពសម្រាប់កម្មករចំណាកស្រុក

➢ *ការលើកលែងទោសទាក់ទងនឹងទិដ្ឋាការ*

សូមឲ្យមានការលើកលែងទោសពេញលេញទាក់ទងនឹងទិដ្ឋាការសម្រាប់កម្មករចំណាកស្រុកដែលគ្មានឯកសារគ្រប់គ្រាន់ ព្រមទាំងសូមបញ្ចប់នូវវិធានការអនុវត្តច្បាប់និងការឃុំខ្លួនទាក់ទងនឹងទិដ្ឋាការ ដោយក្រសួងមហាផ្ទៃ។

➢ *ការការពារពីការរើសអើង*

សូមធ្វើការប្ដេជ្ញាចិត្តចំពោះការមិនសណ្ដោសប្រណីសម្រាប់ករណីជាតិនិយមដោយការស្អប់ខ្ពើមឬការវាយប្រហារទៅលើសហគមន៍ជនចំណាកស្រុក ដោយសារតែវិបត្តិនេះ។

## ៣. សុវត្ថិភាពឧស្សាហកម្ម

➢ *ថាមពលកើតឡើងវិញ*

សូមបញ្ចូលការបង្កើតថាមពលកកើតឡើងវិញនិងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការនាំចេញ ជាសមាសធាតុសំខាន់បំផុតមួយនៃកញ្ចប់ជំនួយសម្រាប់កូវីដ១៩ សម្រាប់បន្តឆ្ពោះទៅខាងមុខ

➢ *ការធានាការងារ*

សូមឲ្យនិយោជកទាំងអស់ធានាការងារ, មិនត្រូវអនុញ្ញាតិឲ្យមានការបញ្ឈប់បុគ្គលិកពីការងារក្នុងអំឡុងពេលនេះ ទោះបីជាការមិនមានវេនធ្វើការក៏ដោយ។ កម្មករនឹងបន្តធ្វើការងារ នៅពេលដែលត្រូវការវេនការងារម្ដងទៀត។

➢ *ភាពជាម្ចាស់សាធារណៈ*

សូមកុំផ្ដល់លុយជួយសង្គ្រោះផ្នែកហិរញ្ញវត្ថុទៅលើវិស័យសំខាន់ចាំបាច់ គឺសូមទិញយកតែម្ដង។ សូមនាំយកអ្វីដែលល្អសម្រាប់សាធារណៈ ត្រឡប់មកជាម្ចាស់សាធារណៈវិញ។

➢ *លក្ខខណ្ឌសម្រាប់ការជួយសង្គ្រោះ*

រាល់ឧស្សាហកម្មទាំងអស់ដែលទទួលលុយពីរដ្ឋាភិបាល ត្រូវបំពេញតាមលក្ខខណ្ឌតឹងរ៉ឹង ស្ដីពីស្តង់ដាការងារនិងបរិស្ថានប្រកបដោយក្រមសីលធម៌។

## ជំហានបន្ទាប់

យើងមានតម្រូវការបន្ទាន់ក្នុងការអភិវឌ្ឍនូវជម្រើសដែលរៀបចំល្អនិងងាយស្រួលយល់ ចំពោះមូលធននិយមដែលស្ថិតក្នុងវិបត្តិនាពេលនេះ។ យើងត្រូវការបង្កើតនិងយល់ព្រមទៅលើការផ្លាស់ប្តូរជាប្រព័ន្ធមួយចំនួន នៃរចនាសម្ព័ន្ធអំណាច ជុំវិញបញ្ហានានា ដូចជាប្រាក់ចំណូលគោលសាកល, ភាពជាម្ចាស់តាមបែបប្រជាធិបតេយ្យ, ការផ្តល់និងការបែងចែកធនធាន, បច្ចេកវិទ្យា និងការតាមឃ្លាំមើល និងសំខាន់បំផុតនោះ គឺវិធីឆ្ពោះទៅកាន់អនាគតមួយជៀសផុតពីវិបត្តិអាកាសធាតុ។

សហជីពរបស់យើង មានសំណាងណាស់ដែលមានមនុស្សជាច្រើនមានការប្តេជ្ញាចិត្តលះបង់ពេលវេលាក្នុងការគិតអំពីបញ្ហាទាំងនេះ ហើយយើងគួរគាំទ្រពួកគេ។

នេះគឺជាឧទាហរណ៍មួយពីហ្គជប្រែ៖ ការផ្លាស់ប្តូរសិទ្ធិនានាដែលត្រូវការចាំបាច់ក្នុងការធ្វើឲ្យយើងត្រៀមខ្លួនរួចជាស្រេចសម្រាប់វិបត្តិលើកក្រោយ ឧទាហរណ៍ កម្មករទាំងអស់ទទួលបានការសម្រាកពេលឈឺ ជាដើម។ សូមមើល https://overland.org.au/2020/03/why-we-need-two-weeks-special-leave-in-the-fight-against-coronavirus/